# ការសំភាសន៍របស់បងស្រី" កួន ស្រី "

ក ៖ អ្នកសំភាសន៍មាន អ៊ុំ កន្និកា ខ ៖ អ្នកដែលត្រូវគេសំភាសន៍ បងស្រី កួន ស្រី

គ ៖ អ្នកចូលរូមក្នុងកាសំភាសន៍គឺជា អ្នកម្ចាស់គោ។

ក៖
ជំរាបសួរបងស្រីហើយជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់បងស្រីដែលបានផ្តល់ឱកាសអោយនាងខ្ញុំធ្វើការសំភាសន៍បងទាក់ទងទៅនិងជីវប្រវត្តិរបស់បងស្រីផ្ទាល់ហើយការសំភាសន៍មួយនេះគឺធ្វើឡើងដោយសាលាសកលវិទ្យាល័យ "ប៊ីវ៉ាយយូ"(BYU) ដោយសារតែសាលាសកលវិទ្យាល័យរបស់យើងមានគោលបំណងចង់ថែរក្សានូវជីវប្រវត្តិរបស់បងទុក...គឺសំរាប់អោយកូនចៅបងជំនាន់ក្រោយអោយពួកគេបានដឹងបានលឺហើយទទួលស្គាល់បានបទពិសោធន៍ល្អៗអំពីជីវប្រវត្តិរបស់បងផងដែរហើយបន្ទាប់ពីការបញ្ចប់នូវការថតសំភាសន៍មួយនេះពួកយើងសុំការអនុញ្ញាតពីបងដើម្បីដាក់សំលេងរបស់បងចូលទៅក្នុងគេហទំព័ររបស់ពួកយើងដែលមានឈ្មោះថា www.cambodia.noralhistories@by.edu ផងដែរហើយខ្ញុំជាអ្នកសំភាសន៍គឺមានឈ្មោះថា អ៊ុំ កន្និកា ហើយកាលបរិច្ឆេទគឺនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ ហើយទីកន្លែងគឺនៅភូមិភ្នំក្រោមផងដែរហើយយើងនិងទៅជួបគាត់ទាំងអស់គ្នា ។សជំរាបសួរបងស្រី......!

ខ៖ ចាំ.....ជំរាបសួរ!

ក៖ តើបងស្រីមានឈ្មោះអ្វីដែរបង?

ខ៖ ខ្ញុំឈ្មោះ កួន ស្រី....!

ក៖ កួន ស្រី.....? បងស្រីជាស្រីហើយឈ្មោះស្រីទៀត...(សើច) អញ្ចឹងតាំងពីខ្ញុំចូលម៉ោខ្ញុំស្គាល់ឈ្មោះបងហើយនិងព្រោះខ្ញុំហៅបងថាបងស្រី....ហ៊ិក ហ៊ិក

ខ៖ ចាំ...និងហើយ!

ក៖ ចុះដូចជាបងស្រីមានឈ្មោះហៅក្រៅទេ?

ខ៖ អត់មានអ្ហែ....!

ក៖ អំ....ចាំអត់មានទេណោះបង?

ខ៖ ចាំ....!

ក៖ គេហៅបងតែស្រីៗនេះឯង!?

ក៖ ចុះរហ័សនាមអីតើបងមានទេ?

ខ៖ អត់ទេ....!

ក៖ ដូចខ្ញុំអ្នាស់បងនៅពីក្មេងគឺម៉ាក់ហៅកាញ៉ាញ់អញ្ចឹងម៉ង!
ដោយសារតែសក់យើងក្រញ៉ាញ់អ្នាស់(សើច)...រហ័សនាម....!

ខ៖ និងអ្ហែ...(សើច)។

ក៖ តើបងមានអាយុប៉ុន្មានហើយបងស្រី....?

ខ៖ អាយុសាមសិបប្រាំឆ្នាំហើយ?!

ក៖ អាយុសាមសិបប្រាំហើយ...! តើចុះបងនៅចាំអំពីថ្ងៃខែឆ្នាំកំណើតរបស់បងដែរទេ?

ខ៖ អឺ......

ក៖ ចង់ភ្លេចហើយណោះបងណោះ?

ខ៖ ចង់ភ្លេច...!

ក៖ អូយ....ភ្លេចឆ្នាំបាត់ហើយអត់អីទេបង...!
ចុះដូចជាទីកន្លែងកំណើតវិញតើបងចាំដែរទេ?

ខ៖ ទីកន្លែងខ្ញុំកើតខ្ញុំកើតនៅភ្នំក្រោមនេះឯង!

កៈ កើតនៅភ្នំក្រោមនេះឯងណោះបងណោះ?

ខៈ ចាំ.....! កើតនៅភ្នំក្រោម!

កៈ គេហៅភូមិភ្នំក្រោម...?

ខៈ និងឯង....!

កៈ ស្រុកសៀមរាបខេត្តសៀមរាប...?

ខៈ ចាំ.....!

កៈ ចាំ....អឺកខាងចុងឃ្មៀសនោះឬក៏ម្ដុំខាងណោះវិញ?

ខៈ ខ្ញុំកើតនៅនិងភ្នំ....កាលខ្ញុំកើតខ្ញុំកើតនៅនិងភ្នំនេះឯង!

កៈ អុំ...ចាំ!

ខៈ នៅខាងណោះភ្នំ!

កៈ កាលបងកើតតើបងកើតនៅផ្ទះឬក៏កើតនៅពេទ្យដែរបង?

ខៈ កើតនៅផ្ទះ....! ចុះកាលនិងយើងមានតែកើតឆ្មបខ្មែរនោះ!

កៈ អុំ....កាលនិងគេមកបង្កើតដល់ផ្ទះ!

ខៈ ចាំ....!

កៈ ចុះដូចជាអឺក...បងមានបងប្អូនប៉ុន្មាននាក់ដែរ?

ខៈ ញុំម....បងប្អូនបង្កើតខ្ញុំមាន....បីនាក់!

កៈ តែបីនាក់ទេ....! ស្រីប៉ុន្មានប្រុសប៉ុន្មានដែរបង?

ខៈ ស្រីពីប្រុសមួយ....!

កៈ ស្រីពីប្រុសមួយ....អញ្ចឹងដូចជាពួកគាត់រស់នៅទីណាដែរសព្វថ្ងៃ?

ខ៖ ប្អូនប្រុសខ្ញុំបន្ទាប់ពីខ្ញុំគេបានប្រពន្ធនៅភូមិព្រៃវែងឯពួកនិងឯង.......

ក៖ អ៎......ចាំ! ចុះចំណែកឯស្រីម្នាក់ទៀត?

ខ៖ ឯប្អូនពៅគេនោះគាត់បានប្តីអ្នកនៅភូមិអង្គរជុំ....!

ក៖ អ៎.....សុទ្ធតែមានគ្រួសាររៀងៗអស់ហើយណោះបងណោះ?

ខ៖ ចាំ....! មានអស់ហើយ!

ក៖ តើគាត់ធ្លាប់មកលេងបងនៅទីនេះទេ?

ខ៖ ម៉ោតាស.....ធ្លាប់ម៉ោតាស!

ក៖ អ៎....ធ្លាប់មកសួរសុខទុក្ខបងដែរ?

ខ៖ ម៉ោ.....!

ក៖
ចុះបងដូចជាបងអាចប្រាប់ឈ្មោះទាក់ទងនិងពួកគាត់ដូចជាថាកូនច្បងនិងមានឈ្មោះអី........បង! បងច្បងមែនទេបង?

ខ៖ ញុំមបងច្បង ញុំមបងគេ!

ក៖
ចុះបន្ទាប់មកទៀតមានឈ្មោះអីគេអញ្ចឹងហើយបងប្អូនបន្តបន្ទាប់ទៀតមានឈ្មោះអីគេ?

ខ៖ គេនោះឈ្មោះ កួន សីនី.......

ក៖ កួន ស្រីនី....? និងប្អូនពៅ?

ខ៖ កួន សីនី....! គេប្រុស!

ក៖ កួន សីនី...! ចាំ(សើច)

ខ៖ និងទីពី...!

ក៖ គាត់ទីពី....ចុះទីបីវិញ?

ខ៖ ទីបីឈ្មោះគេ កូន ណាស៊ី ....

ក៖ កូន ណាស៊ី...!

ខ៖ ចាំ.....!

ក៖ អ៎....ប្អូនស្រីពៅ...ពួកគាត់សុទ្ធតែមានគ្រួសារអស់ហើយ...!

ខ៖ និងឯង.....!

ក៖ ចុះបងដូចជាមានក្មួយប៉ុន្មាននាក់ដែរអញ្ចឹង?

ខ៖ ក្មួយអ្ហោះ....? មាន....ប្អូនប្រុសនោះគាត់មានកូនពីហើយប្រុសមួយស្រីមួយ....!

ក៖ ចាំ....ចុះប្អូនស្រី?

ខ៖ ប្អូនស្រីពៅទើបនិងកូនមួយទេ....!

ក៖ អញ្ចឹងបងមានក្មួយបីហើយ...!

ខ៖ ចាំស....!

ក៖ ចុះបងស្រីវិញមានកូនប៉ុន្មាននាក់ដែរបង?

ខ៖ ប្រាំនាក់....!

ក៖ ប្រាំនាក់អូយ....!
ច្រើនជាងអើប្អូនៗ(សើច)យកកូនអោយច្រើនបន្តិចណោះបងណោះពេលកូនធំទៅអាំង
ជួយជំនួសដៃជំនួសជើងម៉ាក់ខ្លះ....! ដូចជា!

ខ៖
កាលមុនមានហ៊ាននេក...មានហ៊ានពន្យាកំណើតហ៊ានអីឯណាចេះតែខ្លាចៗប៉ះពាល់ទៅអត់ដែរពន្យាកំណើតទេបានជាកូនច្រើន....(សើច)។

ក៖ អ៎....ខ្ញុំស្មានតែបងចង់បានកូនច្រើន...(សើច) តែចុះឥលូវគេមានថ្នាំពន្យាកំណើតមានច្រើនហើយល្អៗណេះបងណេះ?

ខ៖ ចា៎....បងពន្យាហើយ!

ក៖ ល្អៗច្រើន...! ចា៎ចុះដូចជាតើពួកគេសព្វថ្ងៃនិងពួកគេរស់នៅជាមួយបងទាំងអស់គ្នាឬក៏យ៉ាងណាកូនៗរបស់បង?

ខ៖ កូៗខ្ញុំអ្ហោះ?

ក៖ ចា៎....!

ខ៖ អង្កាលពីគាត់នៅរៀនអត់ទាន់បួសនៅជាមួយម្តាយខ្ញុំពីនាក់នៅឯពួក...!

ក៖ អ៎......ចា៎ចុះអ្នកឯទៀត?

ខ៖ បីនាក់រស់នៅជាមួយខ្ញុំរាល់ថ្ងៃនេះកំពុងរៀន....

ក៖ គាត់រៀន.....គាត់រៀននៅម្តុំណាដែរ?

ខ៖ រៀននៅសាលាភ្នំក្រោម....សុវណ្ណភ្នំក្រោម!

ក៖ ចា៎....គាត់រៀថ្នាក់ទីប៉ុន្មានខ្លះហើយបង? ?

ខ៖ អឺក....កូនស្រីទីបីនោះ.....គេរៀនថ្នាក់ទីប្រាំមួយហើយ!

ក៖ ចា៎....!

ខ៖ ដល់ពេលកូនស្រីទីបួននោះ គេរៀនថ្នាក់ទីបី...!

ក៖ ចា៎....!

ខ៖ ដល់តាកូនស្រីទីប្រាំនោះគេរៀនថ្នាក់ទីមួយ....! ទើបនិងចូលរៀន!

ក៖ អ....!
អញ្ចឹងពួកគាត់ត្រូវមួយថ្ងៃៗពួកគាត់ត្រូវការលុយពីបងប្រហែលជាប៉ុន្មានដែរក្នុងការទៅរៀនឬក៏គាត់អត់ទៅរៀនទេ?

ខ៖
គាត់ទៅរៀមអត់ទាន់បានទៅរៀនទេតែគ្រាន់តែទៅមួយពាន់....ម្នាក់មួយពាន់....ពេល..!

ក៖ បីនាក់បីពាន់ហើយណេះបងណេះ?

ខ៖
ចាំ....ពេលដែរម៉ោវិញគឺប្រាំរយហែរទំរាំតែល្ងាចយ៉ាងមិចក៏អស់មួយពាន់ទៀតដែរ...(សើច)

ក៖ អញ្ចឹងត្រៀមប្រាំមួយពាន់ស្រាច់សំរាប់កូនបីនាក់....!

ខ៖ ចាំ....!

ក៖ គាត់ដឹងតែទារ....! តែគាត់រៀនពូកែណេះបងណេះ?
អោយតែរៀនពូកែអោយតែកូនរៀនពូកែដឹងតែអោយលុយចាយអ្វើយអត់អីទេ!

ខ៖ មិនមែនទេ....!
គ្នារៀនមិនសូវពូកែទេប៉ុន្តែបើកូនស្រីទីបួននោះក្នុងខែនេះគេបានចំណាត់ថ្នាក់លេខបួន!

ក៖ ពូកែហើយបង.....! ស្ថិតក្នុងតារាងជាប់បាត់ហើយ....

ខ៖ និងឯង.....! ដល់ពេលកូនស្រីទីបីឯណោះក្នុងខែនេះគេ....បានលេខដប់ពីរ!

ក៖ ចាំ.....!

ខ៖ ចំណាត់ថ្នាក់គេលេខដប់ពីរ....!
ដល់កូនស្រីទីបួនលេខទិចជាងគេ.....អ្លោះកូនស្រីទីប្រាំអ្នាំស!

កៈ ចាំ.....!

ខៈ បានលេខម្ភៃប្អូន...ហាសហា(សើច)ម្ភៃប្អូនក្នុងសិស្សហាសិបនាក់...(សើច)!

កៈ
(សើច)...ម៉្យាងដែរហើយចុះពេលយប់ៗអីបងមានបានបង្កើតដូចថាពេលវេលាដូចថាដើម្បីបង្រៀនគាត់អីមានទេ?

ខៈ
អូយ....ខ្ញុំហត់នឿយពេកហត់នឿយពីពេលថ្ងៃទៅដែលបោកខោអាវបោកអីអោយគេទៅ....ខ្ញុំ!

កៈ សំរាកទៅបងណេះ...?

ខៈ នោះឯង....! អត់សូវបាននេក....

កៈ អត់សូវបានជួយគាត់...ទេ!

ខៈ
អត់បានជួយកូនបង្រៀនកូនទេ...បើបានមើលបានមើលមីទូចក្រោយអំពីការសរសេរអក្សរ រាប់លេខរាប់អី...!

កៈ ចាំ....!

ខៈ តែនិយាយអោយចំទៅបើកូនស្រីទីប្អូននោះខ្ញុំមិចបាច់បង្គាប់គាត់ទេ
ព្រោះអីគ្នាខ្សោយអត់សូវចេះអានមែនប៉ុន្តែអារឿងលេខរឿងអីខ្ញុំអត់ពិបាកបង្គាប់ទេ....
គេឆ្លាតខ្លួនគេបណ្តោយ...!

កៈ គាត់ឆ្លាត...ណេះបង?

ខៈ ចាំ....គាត់ឆ្លាតតាំងពីថ្នាក់ទីមួយអត់ចំបាច់បង្គាប់ទេ!

កៈ អ៉ំ....!

ខៈ គាត់រៀនពូកែ!

កៈ

លើកទឹកចិត្តអោយបងអោយគាត់រៀនដោយសារ....អំណោយទានមួយនិងវាល្អមែនទែន.......

ខៈ ចាំ....!

កៈ ចាំ....អោយគាត់បន្តទៀតគាត់និងមានអនាគតល្អមួយ....! ចុះដូចជាអិម....បងប្អូនរបស់បងនិងដូចជាបងចាំសាច់រឿងទេថាកាលពីក្មេងបងធ្លាប់ធ្វើអីខ្លះជាមួយគាត់អីអញ្ចឹងអីណាស់? ធ្លាប់ទេបង...ដូចថាធ្លាប់ដូចជាបើសិនធ្វើស្រែវិញដូចជាធ្លាប់ធ្វើស្រែជាមួយគ្នាបើសិនចិញ្ចឹមសត្វអីធ្លាប់ធ្វើអីជាមួយគ្នាម៉្យាងដែលជាការចងចាំរបស់បងអញ្ចឹងអ្ហាំស?

ខៈ កាលនៅពីក្មេងឪខ្ញុំបង្ខំឲ្យគោគេអោយមើល....

កៈ អ៎....!

ខៈ មេគោពីរមើលពីនាក់បងប្អូន....

កៈ (សើច)...ចាំចុះបងត្រូវមើលវារបៀបមិចខ្លះដូចថាព្រលឹមឡើងត្រូវយកវាទៅណា? ត្រូវកើបអាចម៍គោត្រូវធ្វើអីអញ្ចឹងអ្ហាំស?

ខៈ ព្រឹកឡើងត្រូវបញ្ចេញចេញក្រៅសិនព្រោះយើងនៅស្រុកស្រែអ្ហោះ?

កៈ ចាំ....!

ខៈ បញ្ចេញក្រៅហើយយើងបោសក្រោលវាអោយស្អាតបានយកវាទៅចងនៅវាល.......

កៈ អ៎....ចាំ....! ចងឯវាលនិងអោយវាស៊ីស្មៅអីនិងអ្ហេសបងអ្ហេស?

ខៈ

និងហើយ.....ចងឯវាលអោយវាស៊ីស្មៅរួច....ពេលណាថ្ងៃឡើងយើងម៉ោ...យើងទៅផ្លាស់អោយទឹកអោយអីហើយយើងទៅរៀន.....!

កៈ ចាំ.....!

ខ៖ ពេលចេញពីរៀនបានយើងទៅយកម៉ោផ្ទះ......!

ក៖ អំ....! តែអត់បាត់ទេណោះបងណោះយកទៅចងក្រៅផ្ទះអញ្ចឹង?

ខ៖ យើងចងអញ្ចឹងអត់បាត់ទេ! ដូចរាល់តែថ្ងៃខ្ញុំបង្វះគោគេពីរដែរ....!

ក៖ បង្វះនិងមានន័យថាយ៉ាងមិចទៅបង?

ខ៖ បង្វះអញ្ចេះ!
គោគឺគោរបស់គេ....ចង់និយាយថាមេរបស់គេ...ពេលណាយើងឃ្វាលយើងមើលថៃពេលគោកើតកូនដំបូងគឺបានយើង....ពេលកូនទីពីបានគេ! មេៗរបស់គេនិងឯង!

ក៖ ចាំ.......!

ខ៖
បើថាយើងមានកំលាំងយើងមើលទៅកូនម្នាក់ពីរយើងអោយទៅគេប្រគល់មេអោយគេវិញក៏បាន...!
ឬមួយក៏យើងថាយើងហត់នឿយហើយ....បានត្រឹមកូនដំបូងរបស់យើងមួយហើយត្រូវផើមត្រូវបានគេយើងអោយទៅគេវិញក៏គេមិនថាអី!

ក៖ ចាំ....!

ខ៖ ចាំ...ព្រោះសំរាប់យើងអត់ដើមទុន! យើងអត់មាន....

ក៖ ចាំ....វាយូរទេបងតម្រាំតែវាផើម...?

ខ៖ គោ...! ដូចជាបីឆ្នាំជាងបួនឆ្នាំអីនិងឯង!
បើតាម....តាមពូចវាដូចថាដូចមនុស្សយើងអញ្ចឹងណាស់តាមវារង្វើហើយនិងកូនញឹក! ដូចគ្នា....

ក៖
ចាំ....ចុះបងគិតថាប្អូនៗរបស់បងគាត់មានអត្តចរិតបែបណា...គាត់ស្លូតគាត់កាចគាត់មានធ្វើអោយបងពិបាកហត់មាត់ឬក៏អីអត់?

ខ៖ ចង់និយាយថាបងប្អូនខ្ញុំនោះ។

ក៖ ចាំ....គាត់មានអត្តចរិតបែបណា?

ខ៖
បើប្រុសគេអត្តចរិតគេចង់និយាយថាគេចង់គ្រប់គ្រងយើងជាបងពាក្យសំដីគេពេលនិយាយម៉ោគឺគេចង់លើយើង......

ខ៖
ពេលដែលគេនិយាយយើងនេះប្រៀបអត់បានស្មើគេដល់ពេលខ្ញុំ....ខ្ញុំអត់ខ្វាយខ្វល់ទេ...ប្អូននិយាយអីនិយាយទៅ!សំខាន់ខ្ញុំអត់តកុំអោយមានរឿង....

ក៖ ល្អ....!

ខ៖ នេះហើយ!

ក៖ ចាំ....ហើយចុះប្អូនស្រីពៅគេអត់អីទេណោះបងណោះ?

ខ៖
ចំណែកឯប្អូនស្រីពៅគេ...ឆុងៗឆាំងៗប៉ុន្តែពេលបងអត់អញ្ចេះក៏បួនប្រាំម៉ឺនពីរបីម៉ឺន....គេអោយ! ប៉ុន្តែពាក្យសំដីពេលដែលថាគេខឹងគេថាអោយយើងអាក្រក់ៗដែរ!

ក៖ ចាំ...អ្នកខ្លះអ្នាំបងសំដីនិយាយពីអាក្រក់ប៉ុន្តែចិត្តវិញនិយាយពីល្អ!
(សើច)អញ្ចឹងអ្នាំស!

ខ៖ ដូចប្អូនប្រុសក៏ដូចគ្នា....!
សំដីគេចង់លើយើងមែនតែតាគេម៉ោគេឃើញយើងអត់អញ្ចេះពីបីម៉ឺនបីបួនម៉ឺន!
តាពេលម៉ោមិនដែលអត់ទេ!

ក៖ (សើច)ម៉្យាងដែរបង....! ចុះដូចជាម្តាយរបស់បងស្រីគាត់មានឈ្មោះអ្វីដែរទៅបង?

ខ៖ ម្តាយខ្ញុំគាត់ឈ្មោះ សេម សុំ....!

ក៖ សេម សុំ...?

ខ៖ ចាំ....!

ក៖ ចាំ....ចុះដូចជាឪពុកវិញបងគាត់មានឈ្មោះអ្វីដែរ?

ខ៖ គាត់ឈ្មោះ គាត់ កួន កឿន...

ក៖ កួន កឿន...! ចាំចុះដូចជាគាត់ទាំងពីនៅឯណាដែរសព្វថ្ងៃបង?

ខ៖ គាត់នៅឯពួកនិងឯងនៅឯភូមិតាតូក...!

ក៖ អំ....នៅខាងពួកនេះឯង....គាត់នៅទាំងពីរនាក់ប្ដីប្រពន្ធគាត់?

ខ៖ តែឪពុកខ្ញុំបួសហើយ....!

ក៖ អំ....ចាំចុះតើបងមានផ្ទះនៅទីនោះអ្ហោះបង? មានផ្ទះនៅឯខាងពួកនោះទេ? ផ្ទះខ្លួនឯងនិងណាស់?

ខ៖ ផ្ទះម្ដាយ......ខ្ញុំអត់មានទេ!

ក៖ ម្ដាយគាត់មានផ្ទះរបស់គាត់?

ខ៖ ចាំ......! គាត់មានផ្ទះរបស់គាត់!

ក៖ អូ......ចាំចុះមូលហេតុអីបានជាបងអត់ទៅនៅខាងម្ដាយហើយបែកមកនៅឯណេះអញ្ចឹងអ្នាំស?

ខ៖ ចង់និយាយថាយើងនៅឯណោះយើងក្រដែរយើងអត់មានដីនៅ...ដីម្ដាយខ្ញុំម៉ាបាទផ្ទះនិងឯង....

ក៖ អូ......ចាំម៉ាគាត់នៅយើងនៅអត់បាន!

ខ៖ នោះឯងមួយបាទផ្ទះតែផ្ទះគាត់មួយនោះឯង!

ក៖ ចាំ....!

ខ៖ ដីរបស់គាត់រកផ្លូវដើរអត់បានទៀតផង....បើដើរៗនិងដីគេ...អើយវាមិនស្រួលទេ...!

ក៖ ចាំ...ទៅបងត្រូវសំរេចចិត្តចាកចេញម៉ោណោះបងណោះ? បើយើងនៅក៏ចង្អៀតចង់និយាយថាចង្អៀតហើយពិបាករស់នៅទៀតដោយសារតែទីកន្លែងយើងរស់នៅវានៅឆ្ងាយពីទីកន្លែងត្រូវប្រកបមុខរបរអីផ្សេងៗអីអញ្ចឹងទៅ!

ខ៖ ប្តីខ្ញុំគាត់...ជាអ្នកនេសាទត្រីកាលណានៅឯណោះគាត់អត់ចេះនៅហើយពិបាករកដែរយ៉ាប់......

ក៖ ចាំ....អ៎....លោកពូជាអ្នកនេសាទ?

ខ៖ ចាំ.....ដូចខ្ញុំអី......

ក៖ អូសំណាញ់អីបង់ត្រីអីចង់រៀនមករៀននិងគាត់បាន....

ខ៖ សំណាញ.....ចងសន្ទូច......

ក៖ មួយកំប្លែណោះបងណោះ? (សើច)ខ្ញុំចងចេះបង់ត្រីឡឹងបង...ខ្ញុំអត់ចេះសោះ! រៀននោះរៀនកប់នោះកប់យ៉ាងណាក៏មិនទៅ....នៅតែ

ខ៖ អូ.....មិនបាច់រៀនទេ......

ក៖ (សើច)មិនបាច់រៀទេណោះបងណោះតាចេះហាត់ណោះបងណោះ?

ខ៖ នោះឯង....មិនបាច់រៀនទេ...!

ក៖ អូ...បងអើយចង់! កុំអោយគេមើលងាយនិងម្លាំស! ថា....

ខ៖ អារឿងការងារប្រុសត្រូវចេះចាំចេះបើមិនត្រូវចេះទេមិនបាច់ចេះទេ! (សើច)

ក៖ (សើច).....ចាំដូចជាម្តាយរបស់បងស្រីគាត់មានស្រុកកំណើតនៅទីនុងតើគាត់ធ្លាប់មកលេងបងនៅទីនេះទេ?

ខ៖ ម៉ោតា....!

ក៖
គាត់ធ្លាប់មកលេងដែរបងណោះពេលមានបុណ្យទានអីម្ដងៗអីអញ្ចឹងអ្នាសឬក៏ពេលបងមានទុកធុរៈដូចជាទម្ងន់អីៗ....

ខ៖ ពេលចូលឆ្នាំ.....និងឯងពេលខ្ញុំមានរវល់គាត់ម៉ោ.....

ក៖ គាត់បានមកមើលថៃយើងដែរ!
ចុះគាត់ជាមនុស្សស្រីដែរមានអត្តចរិតបែបណាទៅបង...?
តាមរយៈដែរបងគិតអីណាស់?

ខ៖ ថាគាត់កាចគាត់ស្លូតគាត់យល់ទុកធុរៈកូនឬក៏អីៗដែរថាជាចរិតរបស់គាត់អ្នាស?

ខ៖ មនុស្សគាត់....មនុស្សគាត់កាចតែគាត់ស្រលាញ់កូន....

ក៖ កាចណោះបងណោះ?

ខ៖ គាត់ស្រលាញ់កូនណាស់!
ពេលខ្ញុំអត់អញ្ចេះពេលគាត់តេទូរស័ព្ទម៉ោគាត់ថាកូនអើយម៉ោៗកូនឯងអត់ម៉ូតូជិះអញ្ចេះកូនឯងម៉ោជិះកង់ម៉ោ....អោយតែខ្ញុំជិះកង់ទៅអញ្ចឹងដឹងតែម៉ោវិញគ្រុនពីរថ្ងៃ...ម៉ោវិញដឹងតែបានប្រាំម៉ឺនប៉ុន្តែដឹងតែគ្រុនពីរថ្ងៃ...!

ក៖ បងជិះកង់ទៅ...?

ខ៖ ជិះកង់ទៅ....!

ក៖ អូ....សាហាវមេះបង...

ខ៖ បើមិនជឿសួរប្ដីខ្ញុំជិះកង់ទៅ....

ក៖ អូយ...បងសាហាវមែន!

ខ៖
យើងអត់មានម៉ូតូជិះ...ហើយបើយើងជិះម៉ូតូអញ្ចេះគ្រាន់តែម៉ូតូឌុបអស់ពីរម៉ឺនទៅបាត់..
....ហើយពីរម៉ឺននោះយើងជិះអ្នកស្គាល់ផងយើងសុំគេផង....!

ក៖ ចាំ......!

ខ៖ ទម្រាំម្តាយអោយប្រាំម៉ឺននោះអស់ល្មម!

ក៖ ហើយបងជិះកង់ទៅប្រើរយ:ពេលប៉ុន្មានទៅ?

ខ៖ អូយ.....ខ្ញុំជិះឃើតខ្ញុំជិះតាមដំណើរអញ្ចេះយូរខ្ញុំ.....

ក៖ ចេញទៅពីម៉ោងប៉ុន្មានទៅ?

ខ៖ ជូនកាល...ខ្ញុំចេញពីម៉ោងប្រាំពីនេះទៅទាល់តែម៉ោងដប់ម៉ោងអីបានដល់...

ក៖ អូ......ជិះលេងៗទៅបងណេះ?

ខ៖ ចាំ......ជិះតាមដំណើរ!

ក៖ អូយ......សាហាវណាស់បង!

ខ៖ ប៉ុន្តែនៅពេលគ្រុនឈឺអស់ហើយតាមអានេះ...តាមអានេះឈឺអស់ហើយ!
តែទៅដឹងតានុងគ្រុនពីរថ្ងៃស្រាច់ហើយ!

ក៖ ចាំ...បងបន្ទាក់ទុនណាស់បងណាស់!
ពេលម៉ោវិញគ្រុនទិញថ្នាំអស់លុយដដែល...(សើច)!
ចាំចុះដូចជាម្តាយរបស់បងគាត់មានប្រកបមុខរបរអីទេនៅទីនោះអ្នាំស?

ខ៖ គាត់....ចាស់ហើយ! គាត់ជួលសំណាញ់អោយគេគាត់ត្រាំម៉ងអោយគេ!

ក៖ អំ......ចាំ.....!

ខ៖ គាត់ចាស់ហើយគាត់ហុកសិបប្រាំមួយអ្ហើយ........

កៈ អូ......គាត់អាយុហុកសិបប្រាំមួយហើយ! ចុះឪពុករបស់បងវិញគាត់មានអត្តចរិតបែបណាទៅបង?

ខៈ មនុស្សគាត់នោះរិះ......!

កៈ អូ...នេះបើគាត់លឺគាត់ថា....

ខៈ គាត់រិះហើយគាត់មឹសៗគាត់អត់ចេះនិយាយទេប៉ុន្តែគាត់រិះ....រិះណាស់មិនងាយទេ....

កៈ អ៎....ចាំ! គាត់ចេះទុកដាក់លុយណេះបងណេះ? (សើច)!

ខៈ (សើច)...ចាំ!

កៈ ចុះដូចជាម្តាយឪពុករបស់បងគាត់ធ្លាប់ប្រៀនប្រដៅបងដោយប្រើពាក្យពេចន៍អីខ្លះដែលបងធ្លាប់ចាំអឺណាស់?

ខៈ ភ្លេចហើយយូរពេក....!

កៈ ភ្លេចហើយណោះបងណោះ? យូរពេក!

ខៈ ចាំ....!

កៈ ចុះគាត់មានធ្លាប់បង្រៀនបងធ្វើម្ហូបឬក៏អីដែរទេ?

ខៈ រឿងម្ហូបរឿងអីបង្រៀនធម្មតាតាស!

កៈ បង្រៀនធម្មតាយើងលួចមើលគាត់ខ្លះអីទៅ!

ខៈ ចាំ......! អញ្ចឹងយើងបានចេះជំនាញតពីគាត់ម៉ោដែរ?!

ខៈ ចាំ.......!

កៈ តើឪពុករបស់បងដូចជាគាត់បួសច្រើនឆ្នាំហើយឬនៅបង?

ខ៖ គាត់បួសអង្កាលឆ្នាំពីរពាន់ដប់មួយ......

ក៖ ពីរពាន់ដប់មួយ...! អ៎....ប្រាំពីរឆ្នាំហើយ!

ខ៖ គាត់បួសនៅកំណើតប្អូនខ្ញុំកើតម៉ោមីក្រោយគេនិងឯងមីប្អូន៧!

ក៖ តែហេតុអីបានគាត់បួសដែរបង? ព្រឿគាត់ចង់ចូលទៅក្នុងអាសនៈធម៌ឬក៏គាត់......

ខ៖ គាត់ចង់ទៅខាងណោះឯង....! គេថាដូចធម្មតារឿង...គេនិយាយផ្លូវធម៌អ្នាស! គាត់ស្ដើងហើយគាត់រកឃើញហើយគាត់ថាអញ្ចេះឯង....!

ក៖ ចា៎....គាត់ចង់ស្គាល់ធម៌ស្គាល់អារ្យគាត់ទៅណោះ!

ខ៖ ចា៎នោះឯង....!

ក៖ ចុះដូចជាគាត់ធ្លាប់ប្រាប់បងទេទាក់ទងទៅនិងការគាត់នៅពីក្មេងគាត់ធ្លាប់ឆ្លងកាត់នូវរឿងរ៉ាវអីខ្លះគាត់ធ្លាប់ប្រាប់បងទេ?

ខ៖ គាត់ប្រាប់តើ.....គាត់ឆ្លងកាត់អង្កាលគាត់ជំនាន់អាពតម្ដាយគាត់ស្លាប់ចោលទៅម្ដាយគាត់ពុលជំឡ្យង...!

ក៖ អឺ.....!

ខ៖ ទៅម្ដាយគាត់ស្លាប់ចោលទៅគាត់នៅក្មេងៗ!

ក៖ ពុលជំឡ្យង?

ខ៖ ចា៎ពុលជំឡ្យង!
ទៅស្ករមានតិចមើសមួយផ្ទះនិងមិនដឹងជាបីនាកឬពីរនាក់ទេដូចអ៊ីខ្ញុំផង...ទៅដល់ពេលស្ករទៅសុំគេទៅគេអោយម៉ាចុងស្លាព្រាទេ...ដល់ពេលនិងទៅគាត់សុខចិត្តអោយកូនអ្នាសគាត់សុខចិត្តស្លាប់ខ្លួនគាត់!

ក៖ អូ....អាណោចអាធ័មណាស់!

ខ៖ កាលគាត់ស្លាប់អង្កាលនោះមាខ្ញុំពៅគេនៅកូនងានៅតូចដែរ!

ក៖ ចាំ...គាត់ប្រាប់បងតាមនិង។

ខ៖ និងឯងថាគាត់វេទនា....!

ក៖
ខំទៅលួចដំឡូងគេទម្រាំបានដល់បានដំឡូងមកញាំហើយឆ្លៀតពុលទៀតអូយ....វេទនាមែនបងអើយបង!

ខ៖ ឪខ្ញុំពេលគាត់នឹកម៉ែគាត់អញ្ចេះគាត់ឡើងលៀដើមត្របែកបានគាត់យំរកម៉ែគាត់....! ពេលនៅដូចថាម៉ោងបួនភ្លឺម៉ោងអីអឺណាស់គាត់ឡើងលើចុងដើមត្របែកបានគាត់ស្រែកម៉ែអើយខ្ញុំនឹកម៉ែឯងណាស់ឪពុកខ្ញុំអញ្ចេះឯងដោយអ្នកជិតខាងគេដំណាលអោយស្តាប់អ្ហាសគេថាស្រណោះកឹកអើយស្រណោះចុះបើឈ្មោះគាត់ហៅក្រៅហៅកឹកនោះគេថាស្រណោះអាកឹកអើយស្រណោះពេលម៉ែវាស្លាប់ទៅវាឡើងលើចុងត្របែកបានវាស្រែកយំរកម៉ែវា......!

ក៖ អូយអាណិតគាត់....! គាត់កំព្រា...ចាំ!
ចុះដូចជាអិម...ដូចជាចាំឈ្មោះយាយតាខាងម្តាយរបស់បងស្រីបានទេថាពួកគាត់មានឈ្មោះអីខ្លះ?

ខ៖ ខ្ញុំភ្លេចត្រកូលហើយខ្ញុំស្គាល់តែឈ្មោះ!

ក៖ ចាំ...តែឈ្មោះក៏បានដែរបង!

ខ៖ យាយឈ្មោះយាយម៉ប់.......

ក៖ យាយម៉ប់.....? និងខាងម្តាយណេះបងណេះ? ចុះតាវិញ?

ខ៖ តា.....! ឈ្មោះតាក្រក......

ក៖ តាក្រក....! ចុះខាងឪពុកវិញបងយាយតាឈ្មោះអីគេដែរ?

ខ៖ មិញយាយតាខាងឪពុកនិងអ្ហាស!

កៈ មិញយាយតាខាងឪពុកណោះ?

ខៈ ចាំ.......!

កៈ ចុះយាយតាខាងម្ដាយវិញ?

ខៈ ខ្ញុំភ្លេចហើយ! ព្រោះអីគាត់ឥស្លាមទៅខ្ញុំភ្លេចឈ្មោះ....

កៈ អ៎....គាត់ខាងឥស្លាមណោះបងណោះ?

ខៈ ចាំ.....! ម្ដាយខ្ញុំគាត់ចាម...!

កៈ គាត់ចាម...! អញ្ចឹងបងកូនកាត់ហើយចឹង! (សើច)!
ខ្មែរឥស្លាម...ចាំអញ្ចឹងបានដូចជាមុខបងស្រស់ណាស់...ដោយសារកូនកាត់សោះ!
(សើច)

ខៈ អូស....ស្រស់ណាស់កញ្ចាស់ហើយ....! (សើច)

កៈ
អញ្ចឹងដូចជាបងមានដឹងសាច់រឿងខ្លះទាក់ទងទៅនិងយាយតាខាងម្ដាយនិងអីយាយតាខាងឪពុកទេ?
ដូចថាឪពុកធ្លាប់និទានថាយាយតាគាត់មានអត្តចរិតបែបនេះបែបនេះគាត់ធ្លាប់ធ្វើអីជាមួយគាត់អញ្ចឹងអ្ហាសដូចថាបងដឹងសាច់រឿរបស់យាយតារបស់បងអ្ហាស? ដឹងទេបង?

ខៈ គាត់មិនដែរសូរនិយាយផងដូចថាណាមួយយាយតាគាត់ស្លាប់យូរហើយ....!

កៈ ចាំ....តាំងពីជំនាន់អាពតម៉ោម្លេះ!

ខៈ នោះឯង......!

កៈ ចាំ...គាត់ប្រាប់តែពីរឿងញុំាជំឡូងនិងអ្ហែណោះបងណោះបង?

ខៈ ចាំ.....! ប្រាប់តែប៉ុននិង!

កៈ ប្រាប់អីផ្សេងអត់មានទេ.....?

ខ៖ អត់ទេ.....!

ក៖
អូ.....ចាំចុះបងស្រីដូចជាមានបងប្អូនសាច់ញ្ញាត្តិអីដែរពួកគាត់រស់នៅក្រៅប្រទេសដែរទេ?
ដូចថាគាត់បែកទៅកាលជំនាន់អាពតអីគាត់បានទៅនៅស្រុកក្រៅស្រុកគេអីអញ្ចឹងអ្នាស?

ខ៖ មានតែខាងម៉ាក់ខ្ញុំ.......!

ក៖ អញ្ចឹងអ្ហោះបង........!

ខ៖ គេនៅម៉ាឡេស៊ី.......!

ក៖
អ៎....គាត់ជាអ្នកបែកអង្កាលដែរជំនាន់អាពតឬក៏គាត់ទើបនិងបែកទៅធ្វើការឥលូវៗដែរទេ?

ខ៖ ឥលូវៗនិងឯង! គាត់បែកជំនាន់អាពតនោះឯង!
គាត់ទៅ...ចង់និយាយថាមួយគ្រួសារគាត់ទោះអាតូចល្អិតល្អក់អីក៏ទៅខាងណោះដែរ!

ក៖ ចាំ....អ៎! ចុះគាត់ធ្លាប់ទំនាក់ទំនងម៉ោទេបង?

ខ៖ គេម៉ោរកតើ....!
ម៉ោ...ម៉ោអង្កាលឆ្នាំដែរខ្ញុំកើតកូនខ្ញុំកាលឆ្នាំពីពាន់ដប់មួយនោះគឺអ៊ុំគាត់ម៉ោផ្ទាល់បណ្ដោយ...ប៉ុន្តែម៉ោផ្ទាល់នោះគាត់មិនសូវជាមានលុយកាក់ទេពីព្រោះអីគាត់មេម៉ាយហើយព្រោះប្ដីគាត់ស្លាប់ហើយប្ដីគាត់ទៅស្រុកគេនោះគាត់ក៏អត់មានធ្វើការងារអីដើរចង់និយាយថាគាត់លក់ក្រណាត់ដើរទូលក្រណាត់អីលក់ទៅណាស់....!

ក៖ ចាំ....គាត់មានមុខរបរតិចតួចនៅស្រុកគេណោះបងណោះ?

ខ៖ ចា.....!

កៈ
ចុះដូចជាគាត់ធ្លាប់ជួយលុយជួយកាក់អីបងទេដូចថាពេលគាត់ម៉ោម្ដងៗអីអញ្ចឹងអ្នាស?

ខៈ គាត់អត់ដែរបានជួយអីខ្ញុំទេ....!

កៈ ដោយសារគាត់អត់ដែរ!

ខៈ គាត់អោយតែប្អូនគាត់...គាត់អោយម៉ាក់ខ្ញុំ!

កៈ អូ....ចប់!

ខៈ
អោយក៏អោយមិនបានច្រើនកាលមោគាត់អោយមួយរយពីររយអីនិងតាមលទ្ធភាពគាត់នោះណាស់!

កៈ ចាំ.....!

ខៈ
ព្រោះគាត់ចាស់ហើយគាត់នៅស្រុកគេនោះគាត់លក់នំអន្សមអាំង...ចាក់នំចាក់ចុលអីលក់ដែរនោះ!

កៈ អំ.....ម្ហូបប្លែកៗដែរថាខាងណោះគេអត់មានយើងធ្វើសំរាប់លក់!

ខៈ
ថាទៅមើលទៅដូចតាយើងធម្មតាអញ្ចេះឯង....នៅដូចតែយើងនៅណោះអញ្ចេះឯង!គះគ្រាន់តែថាលុយគេចាយច្រើនជាងយើង...! ចុះគ្រាន់តែមួយរយរុងគឺតគេស្មើដប់បីដប់ពីរម៉ឺនស្មើលុយថៃមួយពាន់! មួយរយរុងគឺតគេនុង។

កៈ ចុះដូចជារឿទាក់ទងទៅនិងរឿងអាពាហ៍ពិពាហ៍របស់បងស្រីវិញ! ស្វាមីរបស់បងស្រីគាត់មានឈ្មោះអីគេដែរបង(ទៅបាត់លោកពូសើច)។

ខៈ ប្ដីខ្ញុំអ្ហោះ....? គាត់ឈ្មោះ ដួង សំណាង...!

កៈ ដួង សំណាង.......!

ខ៖ ចាំ......!

ក៖ អំចាំ.....ចុះគាត់មានអាយុប៉ុន្មានហើយបង។

ខ៖ គាត់អាយុសាមសិបប្រាំមួយឆ្នាំហើយ......!

ក៖ អញ្ចឹងគាត់បង......បងស្រីតែមួយឆ្នាំទេណោះបងណោះ?

ខ៖ ចាំ.....គាត់បងខ្ញុំមួយឆ្នាំ!

ក៖
ចុះតើបងហើយនិងគាត់បងទាំងពីរស្រលាញ់គ្នាដោយចិត្តនិងចិត្តឬក៏ឪពុកម្ដាយអ្នករៀបចំផ្សំផ្គុំអោយ?

ខ៖ ស្រលាញ់ដោយចិត្តនិងចិត្ត....!

ក៖ អ៊ូ....អស្ចារ្យ...ចុះជួបគ្នាដំបូងនៅឯណាដែរបងហើយកំពុងធ្វើអីដែរ?

ខ៖
ពេលនិងខ្ញុំមកនៅជាមួយបងខ្ញុំមងនៅជាមួយខាងម្ដាយមីងញ៉ុមត្រូវជាជីដូនមួយអ្នាស!

ក៖ ចាំ......!

ខ៖ គេលក់បង្អែមហើយគេហៅខ្ញុំជួយលក់ជួយដូរគេ....ទៅស្គាល់គ្នា!

ក៖ អំ......ចាំ.....! ខ៖ អូយ.....និយាយពីប្រវត្តិប្តីប្រពន្ធខ្ញុំកំសត់ណាស់!

ក៖
កំសត់មែនអ្ហីនហើយបង....ឆ្លងកាត់នូវរឿងរ៉ាវអីគេខ្លះទៅ?ពេលបងការហើយអឺណាស់បង?

ខ៖
ពេលដែរបានគ្នារកលុយបានសែនព្រៃងខ្លួនឯង......សែនខ្លួនឯងហើយពេលដែរបានគ្នាជាគ្រួសារមានកូនប្តីខ្ញុំឈឺច្រើន....កើតបូសត្រចៀក! កើតបូសត្រចៀកទៅ.....វះ! វះកាលឆ្នាំពីរពាន់បួន.....គ្នាឈឺចង់ងាប់ចង់រស់!

កះ ចាំ.....អូកើតបូសត្រចៀក!

ខះ
ពេលដែលយើងក្រណាស់យើងទៅរកខ្ចីគេពេលនិងប្ដីឈឺ......ខ្ញុំប្រាប់អូនឯងគេអ្ហាស គេលក់ដីបានជាងមួយពាន់ដុល្លាពេលយើងទៅខ្ចីអ្ហាសគេអត់អោយយើងទេគេខ្លាចយើងងាប់ទៅអត់បានសងលុយគេ!

កះ បើបងខ្ចីប្រហែលជាបងខ្ចីចំនួនប៉ុន្មានដែរ?

ខះ ចុះអង្កាលនោះគេនៅចាយមាស.....មាសមួយជីដប់ប្រាំបីម៉ឺន!
កាលឆ្នាំពីរពាន់បួនអីនិងអ្ហាស!

កះ ចាំ......!

ខះ
ទៅខ្ញុំត្រូវកំណើតកូនខ្ញុំទីពី......ខ្ញុំទាស់ខ្ញុំឈឺខ្លួនខ្ញុំទាស់ព្រហ្មបចេកសំបកក្រាស់អាចេកស្លាប់មុខយើងនិង!
ដល់ពេលណាប្ដីឈឺអ្ហាសគ្នាអត់បានគេងទេគ្នាឈឺទាំងយប់ទាំងថ្ងៃអត់បានដេកទេគាត់ឈឺខ្លាំងដល់ដំណាក់កាលពេលណាយកសំឡីត្បាលយកខ្ទុះអ្ហាសពេលណាដែរហូរឈាមម៉ោឈាមកកនៅនិងទងត្រចៀកនេះឯងគ្រាឈឺទាំងយប់ទាំងថ្ងៃអត់បានដេកដល់ពេលយើងទៅខ្ចីលុយគេ...!
គេអត់ហ៊ាននិយាយមុខយើងទេគ្រាន់តែទៅដល់នេះចំពោះអ៊ុំខាងគេអ្ហាសខ្ញុំថាអ៊ុំអើយខ្ញុំសូមខ្ចីលុយចងការលុយអ៊ុំឯងមួយជីម៉ោបើអ៊ុំឯងមិនអោយខ្ចីទេឥលូវចងការទៅដូចថាក្នុងមួយជីនិងមួយខែយកប៉ុន្មាននិងអ្ហាស?!

កះ ការប្រាក់....យកការប្រាក់អ្ហាស!

ខះ
ចាំនិងឯង....តែគេអត់អោយទៅគេ...ខ្ញុំទៅខ្លួនខ្ញុំអត់អស់ចិត្តក្រែងលខ្ញុំទៅខ្ចីគេមិនអោយ...ប្ដីដែរឈឺនិងអ្ហាសប្ដូរដើរកោងៗទៅគេអត់អោយទេ... អត់អោយទេ!
ដល់ពេលទាល់តម្រិះខ្ញុំទៅម្ដាយមីងគេនៅផ្ទះធំនេះឯងថាអ៊ីអើយអ៊ីឯងជួយខ្ចីលុយគេ

អោយខ្ញុំមួយជីម៉ោមើលប្ដីខ្ញុំឈឺខ្លាំងទាល់តែគេថាឥលូវបើវាងាប់ទៅប្ដីវាងាប់ទៅវាអត់សងដូចថាខ្ញុំជាប្រពន្ធរកលុយអត់បានសងអ្នាសគាត់អ្នករ៉ាប់ចេញសងអីនោះបានគេអោយលុយខ្ចីម៉ោខ្ញុំប្រាប់...នេះបានគុណបានគុណពេទ្យ" ថន
"តែឥលូវគាត់នៅផ្សារក្រោមទេ!

ក៖ ចាំ....!

ខ៖
ទៅម្ដាយមីងជីដូនមួយប្ដីខ្ញុំគេនាំទៅគាត់ស្គាល់អ្នោះដល់ពេលនាំទៅគាត់មើលជំងឺគាត់ថាអឺសនេក...ត្រចៀកនេះ!
ចង់និយាយថាគ្រាន់តែយើងអត់លុយផងគាត់អាណិតយើងអ្នាសគាត់ថាកាលនោះថ្ងៃទីប្រាំបី...ថ្ងៃទីប្រាំបីអង្គាកណោះមិនដឹងខែប៉ុន្មានទេភ្លេចហើយដែរគេចុះមកស្គាពេទ្យគេចុះមកស្គាបីប្រទេស....ម៉ោនិងពេទ្យខេត្តយើងនេះណាស់!
គេថាបើយើងត្រូវវះអីជំងឺយើងត្រូវវះអីគេវះអោយបានពេទ្យនិងឯងគេវះអោយវះអោយអត់អស់លុយវះអោយគ្រាន់តែខ្ទុះនោះនិងាមអ្នាសជាងកន្លះកន្លោយើងប៉ុននាគ!

ក៖ ពេលនិងមិនដឹងគាត់ឈឺចាប់ប៉ុនណាពេលនិង!

ខ៖
ហ៊ឺឈឺឡើងចង់ងាប់ហើយឈឺឡើងរកខ្មោចយាយខ្មោចតាហើយណាស់....ឈឺឡឹ...!
ឈឺឡឹងបើសិនជាគ្នាអត់បានវះគ្នាត្រូវស្លាប់ក្នុងឆ្នាំនេះឯង....ចុះបើវាដល់ដំណាក់កាលធ្ងន់ធ្ងរហើយនិង...!

ក៖ ខ្ទុះឡើងស៊ីពេញខ្លួនអ្ហើយ!

ខ៖
និងហើយស៊ីទៅពេ់ដែរគេវះទៅគេវះសើយអានេះគេសើយអានេះម៉ោ.....អាខ្ទុះនិងវាស៊ីអាលលាក៏យើងពុកអស់ប៉ុននេះគេរចេញប៉ុនណោះ....

ក៖ ចាំ....សាហាវអាណាអាខ្ទុះនិងអ្នាសបង!

ខ៖

ដល់ពេលវះបានហើយពេទ្យគេប្រាប់យើងថា....អានោះក្នុងយើងខ្វីគេមួយជីនិងណាស់គេយកទៅលក់អោយយើងស្រាច់គេប្រគល់ដប់ម៉ឺនយកមកអោយយើងស្រាច់ប្រាំបីម៉ឺនទុកនៅនិងគេ...ខ្ញុំអ្នាសខំដាំបាយជិះម៉ូតូឌុបទៅ....ទៅអង្គុយចាំគេទម្រាំបានប្ដីវះរួចម៉ោងមួយម៉ោងពីរណាស់!

វះរួចមកដល់ផ្ទះពេលណាគ្មាអស់អាជាតិថ្នាំស្ពឹកនោះគ្មានដេកបានតេស...!

ក៖ អូ....!

ខ៖

គ្នាឈឺខ្លាំង....ហើយពេទ្យគេប្រាប់ថាចុះគេមានអ្នកបកប្រែអ្ហោះ.....គេថាពេលដែលអ្នកឯងមកលាងអ្នកឯងមកលាងនៅនេះម៉ោ...ចង់និយាយថាយើងលាងនៅពេទ្យខេត្តនិងអ្នាស! គេអោយទៅលាងនៅនោះអ្នាស!

ព្រឹកឡើងខំនាំប្ដីទៅ....បើថាគេយកពីរម៉ឺនយើងក៏សុខចិត្តថាអោយគេដែរ...អោយតែអោយតាគេលាងអោយប្ដីយើងអ្នាសដឹងមិចអត់បកមុខរបួសខ្វោកម៉ោវាថាហ៊ីសបើដឹងថាមុខរបួសនេះមិនមែនពួកគេអ្នកវះគេមិនលាងអោយអ្ហួសគេនិយាយភាសានេះអ្នាស! បានខ្ញុំថានេះឯងយើងក្រអ្នាសយ៉ាប់ចអញ្ចេះឯង!

ក៖

ចង់និយាយថាអ្នកដែលតាំងទីអ្នកដែរនៅកន្លែងប្រចាំការនៅនោះនិងគេអត់សូវចង់លាងអោយយើងដូចដែរពាក្យសំដីអ្នកចុះស្ដាម៉ោនិងទេ!

ខ៖

គេអត់ចង់លាងទេគេថាមិនមែនមុខរបួសពួកគេអ្នកវះអ្នាសគេនិយាយគេទៅជាប្រកាន់ជារឿងនោះវិញបើសិនជាយើងអ្នកនេះអ្នាសយើងគួរតែគិតថាអ្វីគ្នាអត់ណាស់គ្នាត្រូវពឹងពាក់យើង...មួយម៉ឺនឬមួយពីរម៉ឺនឥលូវយើងថាយកទៅគ្នាក៏អោយព្រោះអីខ្ញុំតែខ្ញុំទៅខ្ញុំសាគួរលុយខ្ញុំស្រាច់!

ក៖ ចាំ....បង! អោយតែយើងក្រគេមើលងាយហើយបងណេះ?

ខ៖
យ៉ាប់ណាស់មិនស្រួលទេអ៊ីងបានរាល់អាថ្ងៃខំប្រាប់កូនសូម្បីតែកូនដៃរបួសហើយថាកូនអើយ....ម្តាយក្រវេទនាណាស់ហើយលោកពុកក៏អត់ចេះអក្សរគ្មានមុខរបរអីរកពិតប្រាកដឥតលូវកូនខំរៀនទៅកុំអោយម្តាយអស់សង្ឃឹមខ្ញុំប្រាប់ត្រង់រាល់ថ្ងៃខ្ញុំប្រាប់កូនតែពាក្យប៉ុននិងឯងសូម្បីតែកូនស្រីក៏ដោយ....!

ក៖ អោយគាត់ដឹង....!

ខ៖
កូនអើយខំរៀនទៅទោះបីយ៉ាងណាក៏យើងវាគ្រាន់រកការងារអីធ្វើបានស្ពន្ធំសន្ទននិងគេធ្វើគ្រាន់អ្នាស....!

ក៖ ចាំ...! កុំអោយពិបាក!

ខ៖ និងឯង.....!

ក៖ មានរឿងរ៉ាវអីផ្សេងទៀតទេក្រៅពីរឿងប្តីកើតបូសត្រចៀកនិងទេបង....?

ខ៖ អត់មាន....!

ក៖ អត់ទេណោះបងណោះ? ភាគច្រើនរឿងម្ហូបហូបចុកធម្មតាប្រចាំថ្ងៃ!

ខ៖ អឺអារឿងម្ហូបហូបចុកថ្ងៃណាក៏មានថ្ងៃណាក៏អត់!

ក៖ អត់ធ្វើមិចទៅបង? អំបិលប្រហុកទៅណោះបងណោះ?

ខ៖ អំបិប្រហុក...!
ជួនកាលក៏មានញ្ញាត្តិជិតខាងបានគេហុចត្រីឬសម្លរមួយចានទៅ....បានប៉ុននោះឯង! រាល់ថ្ងៃឈឺក្បាលជង្គុងតាសមានបានទៅធ្វើអីកើតយប់ឡើងដេកស្រែកដេក.....

ក៖ បងឈឺក្បាលជង្គុងណោះបងណោះ?

ខ៖ ប្តីខ្ញុំអ្នកឈឺ!

កៈ
បងប្រុសគាត់ឈឺក្បាលជង្គុងហេតុអីទៅបងគាត់មានធ្លាប់កើតហេតុអីកន្លែងនិងអ្វេសឬក៏គាត់ធ្លាប់ធ្វើអីធ្ងន់?

ខៈ
ចង់និយាយថាយើងនឿយដល់ពេលយើងនឿយទៅយើងធ្វើការតាំងពីក្មេងគាត់ធ្វើការលីសែងយើងនឿយហាត់ដល់ពេលយូរទៅវាធ្វើទុក្ខយើងធ្វើទុក្ខសរសៃយើង!
ប្តីខ្ញុំឈឺច្រើនណាស់....! តាំងពីចាប់ដៃបានគ្នាម៉ោគឹតគម្រជាណាស់...!

កៈ គាត់ឈឺរហូត....! គាត់ខ្សោយគាត់ហាត់នឿយជូនកាលគាត់នៅក្មេងរីតាមីនអត់ដល់!

ខៈ ថ្ងៃមុនគាត់ចង់ប្រកាច់ៗ...!
ចង់ប្រកាច់ក៏ទៅពេទ្យខ្ញុំភ័យខ្លាំងក៏រត់ទៅហៅប្អូនជីដូនមួយខាងគេនេះឯងអូនអើយជួយជូនបងឯងទៅពេទ្យបន្តិចទៅបងឯងយ៉ាប់ពេញចឹងជូនទៅគេជួសជាតិស្ករបានតែជិតសិបប្រាំមួយទេនោះទើបនិងហូបបាយហើយផងជាតិស្ករបានតែជិតប្រាំមួយទៅដាក់សារ៉ូមនៅពេទ្យមណ្ឌល....

កៈ ទាល់តែឧស្សាហ៍អោយគាត់ហូបទឹកអំពៅអ្ហោះបងបានឡើងជាតិស្ករវិញ!

ខៈ
ហឺ....ចុះយើងអ្នកអត់អញ្ចេះដូចខ្ញុំរាល់ថ្ងៃបោកខោអាវអោយគេមួយកន្ទ្រែងអញ្ចឹងម៉ោបានមួយម៉ឺនបើទៅផ្ទះធំគេឯណោះគេអ្នកមានគ្រាន់អញ្ចេះដូចថាមួយកន្ទ្រែងអាកន្ទ្រែងប៉ុននេះកំពស់នេះអ្ហោះគេអោយយើងមួយម៉ឺនប្រាំមួយម៉ឺនប្រាំមួយយើងបានហ៊ក....
នោះឯងអាណាម្ហូបផងឯណាថ្លៃកូនទៅរៀន...

កៈ បងទៅទំនាក់ទំនងសុំគេបោកណោះបងណោះ!

ខៈ
ចាំ....ដូចថាគេដឹងថាញ៉ុមបោកអញ្ចេះពេលណាគេត្រូវការគេអោយកូនគេមកហៅខ្ញុំអញ្ចឹងទៅ.....បោកផ្ទះគេអញ្ចេះទៅទឹក
សាប៊ូទឹកក្រអូបអញ្ចេះទៅគេអោយយើងមួយម៉ឺប្រែមួយម៉ឺនប្រាំមួយវាតម្លៃគួរសមដែរ

ណាស់បើសំរាប់អ្នកខ្លះអញ្ចេះមួយកន្រ្វែងម៉ោអញ្ចេះគេអោយយើងមួយម៉ឺនពីអីទឹកយើងសាប៊ូយើងហើយទឹកអញ្ចេះពេលខ្ញុំទិញគេម្តងអស់មួយម៉ឺនប្រាំពាន់....ពាងនោះបីនិងធុងតូចៗនោះឯងសំរាប់ហូបប្រាំប្រាំមួយ!

ក៖ ចុះបងរាល់ថ្ងៃហូបទឹកស្អាតឬក៏ហូបទឹកអីដែរបង?

ខ៖ ខ្ញុំរាល់ថ្ងៃហូបទឹកអណ្តូងធម្មតា!

ក៖ ហូបទឹកអណ្តូងណោះបងណោះ? តែ.....!
ល្អមែនទែនគោរបស់បងបានដូចជាកំពុងឈឺពោះបង្កើតកូនហៀយតិចទៀតវាកើតកូនវាសំរាលកូនហើយ(សើច)វាសំរាលកូនទៅបាន....កូនដំបូងណោះបងណោះអញ្ចឹងបានបងហើយណោះបងណោះ....?

ខ៖ ចាំ....កូនដំបូង!

ក៖ អុំ...បានបងបណ្តោយ!

ខ៖ នេះហើយម្ចាស់គោ(សើច)

ក៖ អុំ....ចាំគាត់ម៉ោប្រាប់ទៀត!
អញ្ចឹងពេលកើតអញ្ចឹងវាមានអ្នកបង្កើតឬក៏វាចេះបង្កើតខ្លួនឯង?

ខ៖ វាកើតខ្លួនឯង....!

គ៖
អត់ចាំបាច់បង្កើតអោយទេតែបើយើងភ័យខ្លាចវាកើតយូរអញ្ចឹងយើងហៅពេទ្យសត្វចាក់ថ្នាំអោយវា....!

ក៖ អុំ.....ចាំ...! ម៉្យាងដែរបង!

គ៖ តែមិនដែរបានហៅផង!

ក៖ តិចទៀតពេលចប់បងទៅមើលគោណោះបងណោះ?

ខ៖ ចាំ......!

កៈ អ៎ចាំចុះចំណែកឯការសិក្សាវិញតើបងរៀនត្រឹមកម្រិតណាដែរបង?

ខៈ ខ្ញុំរៀនបានត្រឹមថ្នាក់ទីប្រាំពីរ!

កៈ ថ្នាក់ទីប្រាំពីរណោះបងណោះ?

ខៈ ចាំ....!

កៈ តែថ្នាក់ទីប្រាំពីសម័យយើងនេះអ្ហោះ?

ខៈ ប្រាំពីរសម័យនេះឯង...!

កៈ អញ្ជឹងបងចេះអានចេះសរសេរអក្សរខ្មែរទាំងអស់ហើយបងណោះ?

ខៈ សរសេរបាន.......!

កៈ ហើយអានក៏បាន......!

ខៈ អានបាន......!

កៈ អញ្ជឹងបងអាចជួយកូនបានច្រើននៅក្នុងការសិក្សារបស់គាត់..?

ខៈ ចាំស.......!

កៈ អូ.....ល្អមែនទែន.....!
ចុះបងកាលបងនៅរៀនបងរៀននៅម្តុំណាដែរសាលារៀនឈ្មោះអីដែរ?

ខៈ កាលខ្ញុំរៀនខ្ញុំរៀននៅសាលា......បឋមសិក្សាតាតូក......!

កៈ តាតូកណោះបងណោះ?

ខៈ នៅភូមិតាតូក......!

កៈ តាតូក.......

ខៈ នៅសាលាបឋមសិក្សាតាតូក!

កៈ ចាំដល់ពេលឡើងម៉ោទៀត.......?

ខៈ ឡើងម៉ោទៀតអនុវិទ្យាល័យពួក......!

កៈ ពួក! អនុវិទ្យាល័យពួក........!
ចុះបងមានធ្លាប់មករៀននៅសាលានៅភ្នំក្រោមនេះទេអត់អ្ហេណេះបងណេះ?

ខៈ អត់ទេ....!

កៈ អ៎...តែកូនបងរៀននៅឯណេះ? ចាំ! ចុះដូចជា....

ខៈ ចាំ....! កូនប្រុសពីរអី...គេរៀននៅសាលាខាងណោះឯង...!

កៈ ចាំ....!

ខៈ កូនខ្ញុំអាប្រុសនោះរៀនបានត្រឹមថ្នាក់ទីប្រាំពីរដែរណេះ!
ខ្ញុំអត់មានលុយអោយរៀនគ្នាឈប់ទៅ!

កៈ ចាំ....! ចុះដូចជាតើបងធ្លាប់មានមិត្តភ័ក្រជិតស្និតកាលនៅរៀនទេ?
ដែរថាបងនៅរាប់អានគ្នាដល់ឥលូវអញ្ចឹងអីណាស់?

ខៈ ខ្ញុំក៏មិនដែរបានទៅ....ទៅសព្វថ្ងៃក៏អ្នកខ្លះគេបានប្ដីទៅនៅស្រុកផ្សេងៗទៅកោះ...

កៈ បែកគ្នាអស់....!

ខៈ ចាំ....បែកគ្នាអស់ហើយ!

កៈ
អ៎...ចាំចុះបងគិតថាជីវិតរបស់បងតាំងពីបងនៅក្មេងរហូតដល់បងអាយុប៉ុននេះអីណាស់បងតើមានការផ្លាស់ប្ដូរហើយឬនៅដូចថា....ពីមុនបងពិបាកឥលូវបងធូរជាងមុនឬក៏ពីមុនបងធូរតែឥលូវបងពិបាកជាងមុនអញ្ចឹងអីណាំការផ្លាស់ប្ដូរមួយនិងអ្នាស?

ខៈ
អីចង់និយាយថាតាំងពីចាប់ដៃបានប្ដីម៉ោគឺថាគ្មានអោយៗមានពេលណាបានធូរពេលណាបានល្ហែរទេ...អញ្ចេះឯង!

កៈ ពិបាករហូតហើយណេះបណេះ?

ខៈ នោះឯង......!

កៈ ចប់ពីមួយរឿងចូលមួយរឿង......!

ខៈ សឹងតែថា......រកសុខមិនបានទេ.......!

កៈ បងពិបាកមែនទែនចាំ.......!

ខៈ អស់ពីររឿងមួយក៏រឿងមួយ.......!

កៈ
អញ្ចឹងពេលបងនៅក្មេងលំបាកបែបនៅក្មេងផ្សេងទៅពេលបងមានគ្រួសារលំបាកបែបមានគ្រួសារទៅ!

ខៈ
ថាលំបាកពេលនៅក្មេងនៅក្នុងបន្ទុកម្ដាយយើងអត់សូវខ្វល់...ចង់និយាយថាម្ដាយរកបានប៉ុនណាបានហូបឬរកមិនបានហូបវាជារឿងធម្មតា!

កៈ ចាំ...!

ខៈ រាល់ថ្ងៃ....រាល់ថ្ងៃចូលថាវអាលំបាកកាយហើអាលំបាកចិត្តទៀត...នោះឯង!

កៈ
អញ្ចឹងយល់អំពីចិត្តរបស់ម្ដាយអ្នាសយើងធ្លាប់តែរស់នៅជាមួយគាត់ឥលូវយើងតួនាទីជាគាត់ម្ដង....ដូចជាឥលូវយើងមកបង្វែអរម្មណ៍ម៉ោណាំខ្ញុំចង់ដឹងថាតើមុខម្ហូបណាដែរបងចូលចិត្តអ្នាសបង
ដូចថាបងញាំទៅបងអាចញាំបាយបានច្រើនដូចថាបងចូចិត្តវាបែបសម្លរឬក៏ឆាឬក៏គ្រៀមក្រោះអីអញ្ចឹងអ្នាស....

ខៈ ត្រីអាំងចំហើយ...ត្រីងាត....

កៈ អាំងណេះបងណេះ?

ខ៖ ចាំ.....!

ក៖ ចូលចិត្តត្រីអាំង.......ចាំ!
ចុះដូចជាការបងនៅក្មេងបងចូលចិត្តលេងល្បែងប្រជាប្រិយ៍អីដែរកាលមានបុណ្យទាន ម្ដងៗតាមភមិអីណាំសបងតើបងចូលចិត្តលេងល្បែងប្រជាប្រិយ៍អីខ្លះជាមួយនិងអ្នកភូមិអ្នាស?

ខ៖
និយាយអោយចំទៅខ្ញុំនិយាយការពិតប៉ាដោយខ្ញុំអារឿងល្បែងល្បាប់អីមិនសូវចូលចិត្តទេតាំងពីក្មេងខ្ញុំមិនដែរចំនួលហើយដូចបុណ្យទានអញ្ចេះណាស់គេអ្នាសអូសទៅបុណ្យជូនកាលអញ្ចេះបញ្ចុះសីម៉ាគេទៅវត្តព្រះអង្គទ្រង់ទៅអីចេះខ្ញុំមិនដែរបានទៅនិងគេតេស......ចុះយើងក្រអត់មានអីជិះហើយគេសម័យនេះកង់ទៅឌុបគ្នាស្មានតាស្រួលអ្នាសហាត់ចង់ងាប់......!

ក៖ ទៅដល់អស់អារម្មណ៍លេងបាត់ណោះបង?

ខ៖
និងឯង......មិនដែរទៅនិងគេទេខ្ញុំមិនដែរបានទៅមិនដែរបានស្គាល់វត្តឆ្ងាយខ្ញុំមិនដែរបានទៅទេវត្តព្រះអង្គទ្រង់ស្គាល់ដោយសារតែលោកពុកខ្ញុំបួសទៅគេយកគាត់ទៅទាក់កងណោះអ្នោះបានខ្ញុំបានទៅ!

ក៖ ទាក់កនិងអីគេបង?

ខ៖ និងភាសាលោកគេហៅទាក់កអញ្ចឹងខ្ញុំមិនដឹងអាមិចទេហៅតាមគេដែរ!

ក៖ ចុះដូចជាចម្រៀងវិញបងតើបងចូលចិត្តស្ដាប់បទចម្រៀងដែរទេ?

ខ៖
អូ......ញ៉ុមចម្រៀងអ្នោះបទសម័យរាល់តាថ្ងៃក៏ចូលចិត្តហើយចូលចិត្តដោយបទទៀត...!

ក៖ ចាំ.......! ចុះបទពីដើមបងចូលចិត្តទេ?

ខ៖ បទពីដើមក៏ខ្ញុំចូលចិត្តចូលចិត្តដោយបទដូចគ្នា!

ក៖ ចាំ.....បទណាស្តាប់ទៅអន្លងអន្លូចណោះបងណោះ?

ខ៖ និងឯង.....!

ក៖ ចុះបងចាំចំណាងជើងទេមើលទៅចាំចំណាងជើងបទដែរបងចូលចិត្តដែរទេ?

ខ៖ អឺសភ្លេចហើយ.......!

ក៖ ភ្លេចបាត់ហើយ.......តែបើស្តាប់ស្គាល់ម៉ងតែលឺស្គាល់?

ខ៖ ចាំតែលឺស្គាល់......!

ក៖
ចាំ......ចុះតើបងមានបំណងថាបងនិងផ្លាស់ប្តូរទីលំនៅទៅស្រុកវិញឬក៏បងនៅតែបន្តរស់នៅទីនេះទៀត?

ខ៖ ខ្ញុំបើកូននៅរៀននេះម្លោះ...ខ្ញុំប្រហែលជាមិនទៅទេ!

ក៖ នៅនេះឯង....!

ខ៖
ចង់និយាយថាពេលខ្ញុំនៅនេះយូរពេលខ្ញុំទៅនៅឯណោះក៏ខ្ញុំអត់ចេះនៅដែរ...ពេលណាខ្ញុំនៅនេះពេលដែរដាច់ខ្លាំងចេះខ្ញុំអាចដើរបោកខោអាវបោកអីអោយគេបានកាលណាយើងទៅនៅឯម្នាសតាអត់គឺអត់ហើយវាអត់ស្រួលទេខ្ញុំអត់ចេះនៅចាំមកនៅឯណោះយូរទៅវិញខ្ញុំអត់ចេះនៅ!

ក៖ ទៅឯណោះអត់ដឹងថារកអី....!

ខ៖ ចាំ.....!

ក៖
ចុះតើបងមានជំនាញអីដែរតពីឪពុកម្តាយដូចថាបងចេះធ្វើផ្តៅចេះធ្វើអន្រ្ទឹងចេះធ្វើអន្រ្ទុតអីអញ្ចឹងអឺណាស់....?

ខ៖ អ៎....អត់ចេះទេ....!

ក៖ អត់ទេបងណោះ..?

ខ៖ ចាំ....តែបើសំណាញ់អីចេះជួសបានបន្តិចៗ....បើម៉ែខ្ញុំគាត់ចេះចាក់សំណាញ់អ្នាស! ប៉ុន្តែខ្ញុំអត់ចេះចង់និយាយថាយើងចាក់ធម្មតាចាក់បានប៉ុន្តែដល់ពេលបំបែកក្មេងវាបំបែកកូនវាខ្ញុំអត់ចេះ។

ក៖ អ៎...ចាំ!

ខ៖
យើងរាប់ទៅជួនកាលក្រឡាអ្នាសដល់ពេលគាត់មនុស្សចាស់គាត់ចេះពីមុនម៉ោគាត.....!

ក៖ គាត់ស្ទាត់....!

ខ៖ នោះឯង....!

ក៖
ចុះបងដូចជាធ្លាប់មានក្តីស្រម៉ៃកាលដែរបងនៅរៀនអ្នាសធ្លាប់មានក្តីស្រម៉ៃចង់ក្លាយជាគ្រូពេទ្យគ្រូបង្រៀនអីមានធ្លាប់ចង់ទេបង?

ខ៖ មាន....! ធ្លាប់ចង់ក្លាយជាគ្រូបង្រៀន!

ក៖
ធ្វើជាគ្រូបង្រៀណោះបងណោះប៉ុន្តែយើងអត់អាចធ្វើបានព្រោះតែជីវភាពអីណោះបងណោះ?

ខ៖ និងហើយ.....!

ក៖
អញ្ចឹងអត់អីបងនៅមានកូនបងជំនាន់ក្រោយបើសិនជា...ជួនកាលគាត់ដុងតាមយើងគាត់ចូលចិត្តមួយនិងដែរអញ្ចឹងគាត់អាចសំរេចគោលដៅបងអញ្ចឹងអ្នាស?

ខ៖
មិនឃើញដែរលោកឪខ្ញុំចាប់ផ្តើមឈឺខ្ញុំឈប់រៀន...រៀនអីរកលុយអត់បានអត់មានអ្នករកលុយអោយរៀនអ្ហាស!

ក៖ ចាំ....!

ខ៖
អញ្ចឹងថ្នាក់ទីប្រាំពីរគេត្រូវការរៀនគួរត្រូវការនេះហើយដល់តែថ្នាក់ទីប្រាំបីទៀតត្រូវការលុយកាន់តែច្រើនទៅខ្ញុំឈប់!
ទៅប្អូនខ្ញុំប្អូនប្រុសខ្ញុំទីពីនោះគ្នាបានត្រឹមថ្នាក់ទីប្រាំពីដែរគ្នាឈប់ធ្វើការសំណង់មួយថ្ងៃរកលុយបានបីពាន់ប្រាំរយធ្វើការសំណង់អ្ហាស...

ក៖ ចាំ....!

ខ៖
មួយថ្ងៃបីពាន់ប្រាំរយហើយដល់តែពេលគ្នាខំរកជួយរកបានប្អូនរៀនផងជួយម្តាយផងប្អូននោះគេរៀនបានចប់ថ្នាក់ដប់ពីគេប្រលងជាប់....ប្រលងជាប់ថ្នាក់ទីដប់ពីអ្ហាសទៅពួកខ្ញុំថាម៉ាពោះបានអីកើតគ្រូមួយទៅព្រោះអីយើងក្ររកអីអត់បានឥលូវបានអីគាត់បានដាក់ពាក្យប្រលងគ្រូទៅកាលនោះសាលាបាយគេចុះទៅសំភាសន៍...ចុះទៅសំភាសន៍ទៅគេចាប់ខាងចុងភៅយើងនេះឯងដល់ពេលសំភាសន៍មុនដំបូងថាអត់ជាប់ទេថាអត់យកគ្នាទេ...ដល់ពេលណាគ្នាទៅលេងកំពង់ឆ្នាំងជាមួយម៉ាក់ខ្ញុំគេមកយកគ្នាទៅថាគ្នាជាប់ប្រថុចញ៉ុចពេកនោះគ្នាម៉ោងណាទាន់...ដល់ពេកនេះទៅគ្នាធ្វើការធម្មតានៅថប់ស្ទ្រីត(Pub street)យើងធម្មតា....ធ្វើបានប៉ុន្មានឆ្នាំបីបួនឆ្នាំគេបានប្តី....បានប្តីទៅរាល់ថ្ងៃគេជាប់ខាងគ្រូ....គេហៅគ្រូកិច្ចសន្យា...

ក៖ គ្រូកិច្ចសន្យានិងមិចទៅបង?

ខ៖
គ្រូកិច្ចសន្យានោះគេ...គេបង្រៀនចង់និយាយថាគេបង្រៀនយើងវាអត់ដូចគ្រូពេញសិទ្ធណាស់ពេលណាគេត្រូវបញ្ឈប់យៀងគេបញ្ឈប់....

កៈ

ចាំ.....ចាំបងចុះដូចជាបងមានពាក្យពេចន៍អីផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយដែរជាកូនចៅរបស់បងអីណាស់ដោយសារតែអិម....សម្លេងមួយនេះគឺលឺដល់កូនចៅរបស់បងដែលគាត់ធំទៅអ្នាស....អញ្ចឹងបអាចប្រើប្រាស់ពាក្យពេចន៍អីទៅកាន់គាត់ដើម្បីជាពាក្យទូន្មានទៅកាន់គាត់ដូចជាពួកខ្ញុំជាសិស្សក៏បងអាចទូន្មានមកកាន់ពួកយើងបានដូចគ្នាចែកចាយទៅក្នុងនិងអញ្ចឹងអីណាំសបង?

ខៈ

ខ្ញុំគ្មានពាក្យអីទេគ្រាន់តែខ្ញុំចង់ថា....សំរាប់កូនខ្ញុំគឺខ្ញុំចង់អោយកូនខិតខំរៀន....ដូចកូនប្រុសដែរខ្ញុំនិយាយអញ្ចេះឯងណាស់បើកូនមានសមត្ថាពអាចរៀនបានក៏កូនរៀនទៅដូចថាទៅធ្វើលោកអញ្ចោះអាចរកបាក់ចៃខ្លួនឯងខ្លះ...វាគ្រាន់ជាងយើងនៅប៉ាសក់អញ្ចេះមិនអាចទៅរកអីបានអ្នាស...! ចង់អោយកូនខំរៀន!
ទាំងអស់ទាំងកូនខ្ញុំទាំងប្រុសទាំងស្រីនិងឯង! អោយកូនខំរៀន។
ពេលណាយើងមានការងារធ្វើយើងចេះអក្សរចេះអីខ្លះទៅយើងវាងាយស្រួលផង......

កៈ ចាំ......! ត្រូវអ្ហើងបង។

ខៈ និងឯង......!

កៈ

ចាំបងពួកយើងដូចជាអរគុណច្រើនដែលបងបានចំណាយពេលវេលាដ៏មានតម្លៃដើម្បីពួកយើងអាចពិភាក្សាគ្នាទាក់ទាងទៅនិងជីវប្រវត្តិរបស់បងស្រីផ្ទាល់អីណាស់បងហើយខ្ញុំបានដឹងថាបងបានឆ្លងកាត់នូវរឿងរ៉ាវជាច្រើនកើតឡើងក្នុងជីវិតរបស់បងរួមទាំងទុក្ខលំបាកនានាដែរបងឆ្លងកាត់ហើយខ្ញុំដឹងថាបងមានភាពក្លាហានគ្រប់គ្រាន់ដើម្បីបងអាចឆ្លងកាត់វារហូតដល់សព្វថ្ងៃនេះ....ហើយខ្ញុំនៅតែលើកទឹកចិត្តបងដើម្បីបងនៅតែបន្តពុះពាររាល់ឧបស្គគទាំងអស់និងដើម្បីកូនៗរបស់បងណាស់បងណាស់ដើម្បីគាត់មានឱកាសបានរៀនហើយធំធាត់ឡើងហើយនិងទទួលបានការងារល្អមួយហើយបកមកវិញហើយគាត់និងលើកទឹកចិត្តនិងធ្វើជាកំលាំងចិត្តដល់បងដើម្បីបន្តដំណើរទៅមុខទៀតហើយដូចជាគាត់និងជួយជ្រុំជ្រែងគ្រួសារគាត់វិញផងដែរ....ហើយពួកយើងដូចជាមា

នអំណរគុណយ៉ាងក្រៃលែងដែរបងបានផ្តល់ដូចជាមានវត្តមានបងនៅក្នុងការសំភាសន៍មួយនិងហើយពួកយើងសុំការអនុញ្ញាតពីបងដើម្បីដាក់សំលេងរបស់បងចូលទៅក្នុងគេហទំព័ររបស់ពួកយើងក៏ដូចជារូបថតរបស់បងផងដែរណាស់បងណាស់?

ខ៖ ចាំស........

ក៖ ចាំ.......ហើយពួកយើងមានតែប៉ុននុងហើយសូមគោរពជំរាបលាបងស្រី...!

ខ៖ ចាំ........!